**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
## រវាង
## រោងចក្រ សូឡាម៉ូដា (ខេមបូឌា) ហ្គាមេន ខូអិលធីឌី
## និង
## តំណាងប្រតិភូបុគ្គលិក និងសហជីពស្មារតីកម្មករខ្មែរប្រចាំ រោងចក្រ សូឡាម៉ូដា (ខេមបូឌា) ហ្គាមេន ខូអិលធីឌី

## ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០២០ វេលាម៉ោង ១៣៖៣០នាទី នៅក្នុងរោងចក្រ **សូឡាម៉ូដា (ខេមបូឌា) ហ្គាមេន ខូអិលធីឌី** មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និង តំណាងកម្មករនិយោជិត សហជីពមូលដ្ឋានប្រចាំរោងចក្រ ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា ដោយសារតែក្រុមហ៊ុនយើងខ្វះការបញ្ជារទិញ ដែលមិនអាចអោយចង្វាក់ផលិតកម្មរបស់រោងចក្រទាំងមូលដំណើរការបាន ហេតុដូចនេះក្រុមហ៊ុន សម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន **២៦នាក់** រយៈពេលចំនួន **៩ថ្ងៃ** គឺចាប់ពី**ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០** រហូតដល់**ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ ២០២០** នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ កម្មករនិយោជិតបានឯកភាពទទួលយកនូវការផ្តល់ជូនរបស់ក្រុមហ៊ុននូវ **ប្រាក់ឧបត្ថម្ភចំនួន ១០(ដប់) ដុល្លាអាមេរិក** សម្រាប់កម្មករនិយោជិតម្នាក់ៗ និងត្រូវបើកប្រាក់ឧបត្ថម្ភនៅ**ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០២០**។

អង្គប្រជុំបានចប់វេលាម៉ោង១៤ និង ៣០នាទី នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួល និង សហការគ្នាយ៉ាងរលូន។

ភ្នំពេញ.ថ្ងៃទី២៧ ខែ សីហា ឆ្នាំ ២០២០

**តំណាងកម្មករ និង តំណាងសហជីព**

ឈ្មោះ ភឿន ស្រីគុច

ឈ្មោះ លី ចន្ថា

ឈ្មោះ ពៅល ស្រីតូច

ឈ្មោះ ណុប វ៉ុន

ឈ្មោះ យិន ណារី

**នាយកក្រុមហ៊ុន**

SOLAMODA(CAMBODIA) GARMENTS CO.,LTD.
KINGDOM OF CAMBODIA

Scanned with CamScanner